បុរសឆ្លើយខ្លីធ្វើឱ្យនាងភ័យព្រួយយ៉ាងចម្លែក។ នាងរវេក្នែកគិតចុះឡើង។

«គីម៉ាល់ ឱ្យប្អូនខ្ញុំមកផ្ទះវិញ!»

នាងស្រដីខ្សោយៗលាក់បាំងសព្ទសំឡេងញ័រ។

«ចង់យកស្អីមកបញ្ហាខាងណោះ អ្ហះប្អូនថ្លៃ! យើងមិនមកជារឿងយើង គ្មានអីនិយាយគ្នាទេ ! Locationសែរឱ្យតែ១០នាទីទេណ៎ា មកទាន់មិនទាន់ រឿងរបស់ខ្លួនឯង»

គេឈប់និយាយ ស្របពេលGPSឱ្យសញ្ញា។ បេះដូងនាងលោតច្របល់....

**ពាក្យកុហកនៅសេសាន**

សូម្បីតែឥឡូវនេះ បន្ទាប់ពីចន្លោះពេលដ៏វែងដែលនាងបើកឡានមករកគេ អារម្មណ៍ភ័យព្រួយសព្វបែបយ៉ាងបានកើតឡើងរួចទៅហើយ។

ទោះបីជាយ៉ាងណា គ្មានការភ័យខ្លាចណាមួយមានទំហំធំជាង សុវត្ថិភាពរបស់និវត្តទេ។

«ប្អូនខ្ញុំជាមនុស្សបានត្រឹមពាក់កណ្ដាលជីវិត! ជីវិតរស់នៅកំដរតែទឹកភ្នែកម្ដាយ បើអ្នកណាដាច់ចិត្តធ្វើបាបវា មានតែគេនោះមិនមែនមនុស្សគីម៉ាល់!»

នាងនិយាយខ្សឹបៗក្នុងឡានម្នាក់ឯងទាំងភ្នែកព្រិលដោយសារសោយសោក។

ពន្លឺក្រហមក្នុងផែនទី Google ឱ្យសញ្ញាដល់នាង។ ស្រីកម្សត់ជូតទឹកភ្នែក ហើយបង្អន់ល្បឿន។ ទិសខាងស្ដាំជាកន្លែងនាងត្រូវទៅ តែជាតំបន់វាលត្រែងស្ងាត់និងងងឹតព្រាលៗក្រោមពន្លឺចង្កៀងសូឡាតិចតួច។

តើគេចុះទៅនៅក្នុងទន្លេធ្វើអីទៅ?

ឬក៏ទូករបស់គេនៅទីនោះ។

«ចុះពីឡានមក!»

សារលោតឡើងមកឆ្លើយតបនឹងចម្ងល់នាង។

ស្រីស្អាតឱនពិនិត្យផង បេះដូងបន្ថែមល្បឿនលោតរបស់វាឡើងជាលំដាប់ផង។

ពីក្រោយខ្នងនាង បុរសពីរនាក់បង្ហាញខ្លួន។ ហាន់ដា ងើបមុខយ៉ាងរហ័សសម្លឹងតាមកញ្ចក់មើលក្រោយ។ ម្នាក់ជាវុធនាងចំណាំបាន ឯម្នាក់ទៀតនាងមិនស្គាល់ទេ។

ស្រីស្អាតឈ្ងោកមកចុចសួរតបវិញ៖

«ចង់ធ្វើអីខ្ញុំ?!»

គ្មានចម្លើយ។ នាងស្រវាចុចទៅរកគេតែគ្មានគ្មានអ្នកលើក។ គេលេងក្បួនអី មនុស្សចម្លែងនេះ។ ស្រីស្អាតកើតទោសៈផង ខំតតាំងនិងការភ័យខ្លាចផង។

ស្នូរគោះកញ្ចក់ បានពញ្ញាក់នាងឱ្យភ្ញាក់ព្រើតសឹងរបូតទូរសព្ទ។ នាងនៅជំអក់ មុនពេលសម្រេចចិត្តបង្អើបកញ្ចក់ហើយសួរដាច់ៗ៖

«គីម៉ាល់នៅឯណា?!»

«គាត់ចាំក្នុងផ្ទះ!»

ទីនេះមានផ្ទះ?

ហាន់ដារវ៉ៃភ្នែកសម្លឹងជុំវិញខ្លួន។ ទោះយ៉ាងណា  នាងមិនអាចបដិសេធបានទេ នាងដឹង។ មាណវីឈ្ងោកចុចសារទៅរកគេបន្តទៀត៖

«គីម៉ាល់ ! ខលមកខ្ញុំភ្លាម!»

«ខ្ជិលណាស់! ចង់និយាយគ្នាតទល់!»

ទោះយ៉ាងណានាងអរណាស់ពេលឃើញអក្សរគេ។ គេនេះចម្លែងបំផុតដែលមិនព្រមលើកទូរសព្ទ តែវាយសារត្រឡប់មកវិញលឿនហួស។ គេកំពុងសប្បាយក្នុងការយកយើងធ្វើជាល្បែងលេងសើចពិតណាស់។

«ខ្ញុំភ័យ!  ដឹងអត់គីម៉ាល់! ខ្ញុំភ័យណាស់!»

នាង Voice ទាំងញាប់ញ័រ។ មនុស្សទាំងពីរប្រាណនៅអត់ធ្មត់រង់ចាំខាងក្រៅឡាន ខណៈនាងលើកដៃជូតទឹកភ្នែកព្រោះមិនដឹងត្រូវសម្រេចចិត្តយ៉ាងណា?

មេឃរកផ្កាយមួយគ្រាប់គ្មានទេ។

ស្រុកសេសាននេះសម្បូរទៅដោយព្រៃឫស្សី និងវាលត្រែងឆ្ងាយដាច់អាល័យពីភូមិ តើគេនេះហៅមនុស្សស្រីវ័យក្មេងម្នាក់ មកកន្លែងនេះបែបនេះដើម្បីអ្វីទៅ? គេមិនមែនសាហាវដល់ថ្នាក់អាចប្រើមនុស្សមកសម្លាប់យើងចោលនៅកណ្តាលព្រៃត្រែងទេដឹង?

ស្រមោលមនុស្សបង្ហាញខ្លួនពីចម្ងាយ។

គេនោះដើរមកប្រឆាំងនិងហ្វាឡានចិញ្ចាចរបស់នាង ក៏ប៉ុន្តែត្រឹមមួយក្រឡេកប៉ុណ្ណោះ នាងដឹងថាគេជាអ្នកណាទៅហើយ។

ស្រស់ស្រីនៅអង្គុយយំផ្ទឹងក្បែរចង្កូតទាំងខឹងបុរសនេះ ចំណែកអារម្មណ៍សម្ងាត់មួយទៀតគិតអំពីប្អូនប្រុស។

នាងនៅតែមិនទាន់ហ៊ានចេញពីជំនិះ។

បុរសដល់ទៅបីនាក់នៅខាងក្រៅ សុបិនអាក្រក់ច្រើនជាងសុបិនល្អសម្រាប់នាងក្នុងរាត្រីនេះ។

ទីបំផុតគេមកដល់ហើយ គឺនៅពីមុខឡាននាង។

ប្រសិននាងជាន់ហ្គាតែបន្តិចរាងកាយនិងសម្តីផ្តាច់ការបញ្ជាគ្មានញញើតរបស់គេអាចនឹងរាបដល់ដីបាន។

ទោះយ៉ាងណានាងមិនបានធ្វើទេ។ រហូតដល់គេដើរមកក្បែរហើយលូកដៃទាញបើកទ្វារ។ នាងស្រវាចុចគន្លឹះបើក យ៉ាងងាយស្រួលមិនចាំបាច់បង្ខំ។

ផ្ទៃមុខស្រស់សង្ហាដែលកាលពីម្សិលបានធ្វើ ឱ្យនាងជំពាក់ភ្នែក ពេលនេះនៅជិតបង្កើតសារជាថ្មី។ គេញញឹមតិចៗឱនមកមើលនាងទាំងគ្មានវាចាមួយម៉ាត់ណា។

ភាពមិនសប្បាយចិត្តមួយ ឬភាពស្មុគស្មាញមួយចំនួនបានបង្កប់ក្នុងជម្រៅកែវភ្នែកបុរសនេះ។ នាងសម្លឹងគេក្រឡង់ទាំងដៃនៅកាន់ចង្កូត ឯក្នុងគំនិត មិនបានរកឃើញអ្វីដែល បង្ហាញថាមានប្រៀបក្នុងឆាកប៉ះទង្គិចលើកនេះឡើយ។

«បាត់ភ័យនៅ!»

គេថ្លក់គ្រាប់ភ្នែកនារីជាប់ក្នុងការសម្លឹងអណ្តែតអណ្តូងហើយថែមទាំងសួរស្រាលៗឌឺដង។

នារីនេះនៅតែបន្តសម្លឹងគេថ្លែរ។ គេដឹងថា នាងកំពុងមើលចិត្តនាយ និងព្យាយាមទាយអំពីវាសនារបស់ខ្លួនក្នុងល្វែងរាត្រីនេះ។

«ចុះម៉ោ!»

គេក្រោកខ្លួនឡើងវិញលែងឱ្យនាងមើលមុខក្រែងស្រីដឹងចិត្តនាំតែពិបាកបង្ក្រាប។ ដឹងអីនាងនៅតែមិនព្រមធ្វើចលនាតាមបង្គាប់ បែរជាវេភ្នែកសម្លឹងជុំវិញខ្លួនបន្ថាយពេល។

បុរសលូកដៃមកចាប់កដៃឆ្វេងនាង។

ដៃនាងត្រជាក់ស្រេង ឯប្រអប់ដៃនាយវិញក្តៅឧណ្ហៗហាក់មានថាមពលបន្ថែមភាពព្រួយភ័យដល់ហាន់ដា។

នាងដឹងហើយថាប្រអប់ដៃនេះមិនងាយនឹងរើទេ ។ មិនទាន់អីផង គេលូកដៃម្ខាងទៀតមករុញទូរសព្ទដៃនាងចេញឆ្ងាយទៅកៅអីម្ខាង ហាក់ចង់ប្រាប់ថាមិនបាច់កាន់មកទេ។

ស្រីស្អាតក្រោកចេញយឺតៗ។ ដៃស្តាំស្រវាដកសោឡានយកមកកាន់ផង។

នាងមិនបានបិទទ្វារឡាននៅឡើយ ម្ល៉ោះហើយខាងប្រុសរុញបិទទៅវិញគ្រប់ជំនួស។

«ប្អូនខ្ញុំនៅឯណា?!»

នាងសួរញ៉េរៗក្រោមចំហាយរាត្រីកាលដ៏ត្រជាក់សុខដុមរមនាមាត់ទន្លេស្ងប់ស្ងាត់។ បុរសនេះមិនឆ្លើយ ថែមទាំងទាញយកសោមកចុចបិទគន្លឹះឡានឱ្យបន្ថែម។

ដោយគេអូសដៃទៅនាងត្រូវដើរទាំងចិត្តចង់ខ្លះ មិនចង់ខ្លះ។ ចិត្តចង់ព្រោះតែគិតប្អូន ចំណែកចិត្តមិនចង់ព្រោះគេនេះច្បាស់ណាស់នឹងនាំរឿងរ៉ាវដល់ខ្លួនមិនខាន។

វុធនិងម្នាក់ទៀតបាត់ស្ងួន្យពីពេលណាមិនដឹង។

ទីនេះមានតែវត្តមានប្រុសស្រីពីរនាក់ដែលម្នាក់កំពុងលាក់ទុក្ខកង្វល់ជាច្រើនពេញលង្វែកទ្រូង ម្នាក់ទៀតកើតទុក្ខសង្ស័យ ខឹងសម្បារ។

អ្នកខឹងសម្បារគឺនាង។ នាងដឹងថាអ្វីទៅដែលជាដើមចមនៃទុក្ខសោកក្នុងគ្រានេះ។ ស្រស់ស្រីគិតថាមានតែសម្រេចចិត្តផ្តូងៗឆាប់ៗប៉ុណ្ណោះនឹងអាលឆាប់ចប់រឿង។ នាងចាប់ផ្តើមនិយាយៈ

«គីម៉ាល់ ខ្ញុំព្រមផ្ទេរសណ្ឋាគារជាមួយលុយទាំងអស់នោះឱ្យ ខ្ញុំមិនត្រូវការទេ ឈប់តាមចងពៀរខ្ញុំ!»

មុននេះគេហាក់សប្បាយចិត្តណាស់ ដែលបានដឹកដៃប្អូនស្រីក្រោមរាត្រីរនោចគ្មានមាររំខាន ស្រាប់តែនៅមិននៅ ខាងនាងបែរជានឹកឃើញវែងហួស ទៅលើកយកប្រធានបទលុយមរតកឡើងមក ភាពមិនសប្បាយចិត្តសារជាថ្មីបានអណ្តែតមកបំពុលបរិយាកាស។

នាងដឹងតាមរយៈដៃគេដែលរឹតនាងតឹងជាងមុន។

គេដើរញាប់ឡើងមិនគិតដល់នាងដែលទាបជាងជើងខ្លីជាងនោះទេ។ នារីត្រូវបង្កើនល្បឿនទ្វេឡើង និងតាមតត្រុកទាំងហត់នឿយកាយចិត្ត ទាំងខឹងក្នាញ់នឹងភាពស្ងាត់ស្ងៀមរបស់គេ ។

«គីម៉ាល់ ខ្ញុំនិយាយមែន!»

ដង្ហើមនាងដង្ហក់ព្រោះហត់ធ្វើ ឱ្យបុរសព្រមឈប់សំចត។ គេរលាស់ដៃនាងចេញហាក់ខឹងសម្បារ។

នាងប្រឹងរំងាប់ដង្ហើមដែលហត់គឃូសមុនពេលនិយាយទៅកាន់មាឌធំជង្គ្រោងដែលកំពុងឈរច្រត់ចង្កេះ ធ្វើមុខស្មើដាក់ខ្លួន។

«ឱ្យប្អូនខ្ញុំចេញមក! យើងនិយាយគ្នាត្រង់ណេះបានហើយ! ចង់បានលុយវិញតើមែនអត់? ខ្ញុំឱ្យវិញយកអីយកទៅ ហើយចេញឱ្យផុតពីជីវិតខ្ញុំ!»

គីម៉ាល់ដៀងភ្នែកដែលចេញចំហាយក្ដៅឡើងៗដោយភាពសៅហ្មង មកពិនិត្យឫកពាធ្វើហំហានហាក់មានថាមពលខ្លាំងនៃនារីនេះ។ នាងមានប្រុសស្អាតៗនៅជុំវិញខ្លួន ទាំងសពប្ដីនៅមិនទាន់រួចផុតបាន ១០០ថ្ងៃជារឿងមួយហើយ ពេលនេះមកឡូយឆាយនិយាយដាក់បងថ្លៃដូចអស្ចារ្យមកពីស្ងួតទៀត ទំនងនាងគិតថា ទោះព្រមរបូតមរតករាប់លានហើយ ក៏នៅមានច្រកផ្សេងបើកវាតវង់រង់ចាំច្រើនដឹង?

«មិនមែនខាងខ្លួនជាអ្នកសម្រេចចិត្តទេ!»

គេនិយាយហើយខាំមាត់តិចៗ តបតនឹងកែវភ្នែករបស់ថ្លាមុតទាំងគូ។ ខាងស្រីងាកមុខចេញហាក់មិនចង់មើលភាពខឹងរបស់គេ ដែលម្ដងៗបេះដូងនាងចេះកើតភាពពិភាល់ភ័យ។ ទឹកមុខគេនេះមានអំណាចសឹងអាចបំភ័យនាងបាក់ម្ដងៗបាន ម្ល៉ោះហើយសម្លឹងទេសភាពស្រអាប់ប្រសើរជាងសម្លឹងគេ។

ទ្វាររបងដើមរុក្ខជាតិប្រជ្រៀតញឹក ឡោមជាមួយបុប្ផារាត្រីក្រអូបសាយបង្ហាញខ្លួនក្រោមកូនអំពូលពងមាន់តូច។

ហាន់ដាទើបនឹងសម្គាល់ដឹងថា មានកូនផ្ទះឈើប្រមាត់ច្រាំងមួយ បង្កប់ខ្លួនក្នុងសំណុំ រុក្ខជាតិព្រៃត្រែងសៃនឯកោស្ងប់ស្ងៀម។

នាងកំពុងពិនិត្យគ្រប់យ៉ាងស្រាប់តែបុរសនេះលារង្វង់ដៃមកក្រសោបស្មានាង។

សៃនភ្ញាក់ផ្អើលចំពោះអាកប្បកិរិយានេះនាងរើរុះប្រតាយប្រតប់។

ទោះបីប្រើតែហត្ថាម្ខាង គង់គេអាចជម្នះកម្លាំងរើរុះរបស់នាងបាន។

«ប្រុសៗចូលចិត្តណាស់ពួកស្រីឆ្នាសៗ របៀបហ្នឹង!»

គីម៉ាល់និយាយទាំងអូសបង្ខំនាងចូលទៅក្នុងរបង។ ហាន់ដាខំប្រតោងប្រទាមរាបអស់ពពួកស្មៅនិងកូនរុក្ខជាតិអមសងខាងផ្លូវឆ្ពោះទៅរកកូនផ្ទះឈើដែលនៅ ជ្រៅប្រមាណជាង៣០ម៉ែត្រពីទីនេះ។

នាងក្រឡេករកមើលអ្នកស្រុក និងត្រៀមជាស្រេចក្នុងការរកមើលជំនួយ។ គ្រប់យ៉ាងងងឹតហើយគួរឱ្យខ្លាច ផ្ទះនៅខាងចុងមានតែពពួកអំពូលតូចផ្លុងៗ ហាក់បីដូចជាដាក់បំភ្លឺឱ្យតែមាន។

នាងប្រតោងដៃបុរសជាប់ហាក់ទទូចកុំឱ្យគេបន្តដំណើរទៅមុខ។ គីម៉ាល់ទទួលអារម្មណ៍ដឹងអំពីទុក្ខព្រួយរបស់នាងទើបខាងប្រុសទន់ចិត្តបង្អន់ឈប់។

«កុំធ្វើបាបខ្ញុំ ទោះយ៉ាងណាខ្ញុំជាប្អូនថ្លៃ ជាកូនប្រសាររបស់ប៉ា! យល់ដល់ប៉ា លែងខ្ញុំទៅគីម៉ាល់»

គេសម្លឹងនាងស្វាត់ស្មៀម ទុកឱ្យនារីនេះឈរជូតទឹកភ្នែកតាមសប្បាយ។ ដោយមានឱកាសនាងនិយាយបន្ថែមទាំងអណ្ដឹតអណ្ដកៈ

«លុយអស់ហ្នឹង ខ្ញុំមិនដែលប្រាប់ពិសិដ្ឋ ឬមួយធ្វើល្បិចអីឡើងឱ្យគាត់ផ្ទេរមកឱ្យខ្ញុំទេ! ខ្ញុំនិយាយទាំងអស់នេះជាការពិត! ឥឡូវនេះបើបងប្រុសគេ ត្រឡប់មកវិញហើយ ខ្ញុំក៏អស់ភារកិច្ចអីត្រូវនៅមើលថែទៀតដែរ ខ្ញុំដកខ្លួនខ្ញុំចេញ ខ្ញុំសូមដកខ្លួនមែន! ទុកតែជីវិតឱ្យខ្ញុំ ទុកសេចក្ដីសុខឱ្យគ្រួសារខ្ញុំប៉ុណ្ណឹងបានអត់ខ្ញុំសូមអង្វរ»

«ម្សិលមិញ ប្រាប់ឱ្យមកជួបគ្នា ម៉េចស្ដាប់គ្នាមិនបាន?!»

បុរសសួរវិញតិចៗ តែមិនបានឆ្លើយតបនឹងសំណួររបស់នាងទេ។ នាងឆ្លើយមិនចេញចំពោះកែវភ្នែកមុតថ្លារបស់គេដែលកំពុងសម្លឹងមក ថែមទាំងមានអារម្មណ៍ថា គ្មានទំនងណាដែលសមនឹងជឿថាគេព្រមដោះលែងនាងត្រឡប់ទៅផ្ទះបានងាយៗឡើយ។

«យើងគិតខុសឬត្រូវដែលមិនឱ្យជេនមក!»

សំណួរនេះលេចឡើងពេលដែលក្ដីសង្ស័យកាន់តែពិបាកសង្កត់។

«ឱ្យប្អូនខ្ញុំចេញមកគីម៉ាល់! ឈប់លេងសើចជាមួយការបារម្ភរបស់ខ្ញុំ!»

បុរសនេះស្រាប់តែងក់ក្បាលលឿនជាងការរំពឹងទុក។

នាងមិនសប្បាយចិត្តទេព្រោះនាងមិនឃើញមានចេតនាល្អអីបន្តិចណាក្នុងឫកពារបស់គេ។

«បើបងគេនៅ គេទៅបាន!»

គីម៉ាល់បន្តយឺតៗ ដោយញាក់ចិញ្ចើមដាក់ប្រស្រីខ្មៅយង់នៅនឹងមុខខ្លួននេះផង។

អារម្មណ៍ធ្ងន់ធ្ងរមួយ បានឆ្លងកាត់ញាណពិសេសរបស់នាង។ ការកាប់សម្លាប់ហាក់លែងចោទជាបញ្ហាទៀតហើយ អ្វីដែលត្រឡប់មកវិញគឺរឿងរ៉ាវកាលពីម្សិលមិញ។

«កុំឱ្យសោះរឿងគិតចង់រត់ ទោះទៅដល់ជើងមេឃណាក៏នៅតែត្រូវត្រឡប់មកវិញដែរ!»

នាងគ្រវីក្បាលយឺតៗ ទាំងមាត់គ្មានចម្លើយ ទាំងភ្នែកនៅសម្លឹងភាគីខាងប្រុស។ ពន្លឺភ្នែកនាងគឺភ័យផង គ្មានដំណោះស្រាយផង។

ដៃបុរសលូកមកវែកសក់នាងដែលប៉ើងបិទបាំងវង្សភក្ត្រស្រស់ស្អាតដូចខែ។ ដូចគេគិតទុកមែន នាងលើកដៃមកវាសច្រានម្រាមគេចេញភ្លាមតែក៏ត្រូវខាងប្រុសចាប់បានភ្លាមៗដែរ។ ដៃនាងត្រជាក់ ស្មើនឹងបេះដូងដ៏ត្រជាក់ដែលអ្នកកំពុងមានក្នុងប្រអប់ទ្រូង។

ភ្លើងចង់បាន ភ្លើងមានះនៅក្នុងភ្នែករបស់គីម៉ាល់ ធ្វើឱ្យនាងភ្លាត់មាត់៖

«នេះជាស្រុកមានច្បាប់ ខ្ញុំអាចប្ដឹងដែលប៉ះពាល់បំពារបំពានខ្ញុំ!»

គេប្រើតែចុងបបូរមាត់ប៉ុណ្ណោះ ក្នុងការសើចចំអកដល់ការសម្លុតរបស់ប្អូនថ្លៃ។ ចរិតអំនួតនេះបានលេបត្របាក់ការអាណិតទោរទន់ដែលធ្លាប់មានទាំងប៉ុន្មាន។

គីម៉ាល់នឹកឃើញមួយរំពេចដល់រូបរាងប៉ូលិសជេន ដែលហ៊ានមកទទួលប្អូនថ្លៃដល់ដៃ ចំណែកកាលទៅពេទ្យបាត់ពេញមួយព្រឹកមិញជាមួយនាយសុងសក្តិ ទៀតសោតគេនៅមិនទាន់បានរំឭកទូទាត់នៅឡើយ។

ហាន់ដាប្រើម្រាមដៃម្ខាងទៀតដើម្បីទាញប្រអប់ដៃគីម៉ាល់ចេញ តែទាញមិនបានមានតែខ្លួនឯងដែលត្រូវគេទាញចូលផ្ទះបានសម្រេច។

ទីនេះជាផ្ទះឈើ មានលំហខាងក្រោយលយទៅក្នុងទឹក សមថាជាពពួកផ្ទះប្រណីតតូចៗសង់ឡើងសម្រាប់ជួលបម្រើអ្នកទេសចរចូលសំណាក់ ហើយពួកគេបានរៀបចំវាឡើងពេលមានគម្រោងមកកាន់ស្ទឹងត្រែង។ អ្វីដែលមិនស័ក្តិសមនោះ គឺបរិយាកាសស្ងាត់ណាស់ ជាផ្ទះជួលគួរតែមានបន្ថែមច្រើនទៀតនៅបរិវេណក្បែរៗគ្នា ម្ដេចក៏មិនឃើញមានទៀតសោះ?

នាងរលាស់ដៃបុរសនេះចេញពេលគេឈោងដៃទៅបើកវាំងននបង្ហាញទិដ្ឋភាពក្រៅកញ្ចក់។ លើកនេះគេលែងដៃនាងមិនពិបាកដូចនៅខាងក្រៅទេ។

នាងប្រុងនឹងរត់បកក្រោយដែរ តែអ្វីមួយនៅមាត់ទឹក បានទាក់ទាញនាងឱ្យទ្រឹងភាំង។

កូនទូកមួយរំជួលម៉ាស៊ីនចាកចេញពីច្រាំង ហើយនៅលើនោះមានមនុស្សប្រុសពីរបីនាក់។ ម្នាក់ដែលនាងសម្គាល់ច្បាស់ជាងគេ គឺប្អូនប្រុសខ្លួន និវត្ត។ គេកំពុងកាន់អ្វីម្យ៉ាង មានរាងដូចជាម៉ាស៊ីនថតព្រមទាំងផ្ទង់សប្បាយជាមួយទេសភាពធម្មជាតិខៀវស្រអាប់។

«និវត្ត?!»

នាងហៅតិចៗទាំងស្លុតចិត្ត។

ស្នាមញញឹមមួយបានគ្របមកលើផ្ទាំងកញ្ចក់ ជាការឆ្លើយឆ្លងនឹងទុក្ខសោករបស់នាង។ បបូរមាត់មនុស្សនៅពីក្រោយខ្នងហាន់ដា បានទាញចិត្តនាងឱ្យអស់សង្ឃឹម។

នាងគ្រវីក្បាលតាមសម្លឹងកូនទូកដែលថយឆ្ងាយទៅៗចោលមាត់ច្រាំង មុនពេលរវៃភ្នែកសើមល្អក់ទាំងសងមកសម្លក់អ្នកជះស្រមោលក្នុងផ្ទាំងកញ្ចក់ថ្លាត។

«ប្អូនខ្ញុំវាមិនដឹងរឿងអីទេ!»

សំឡេងនាងខ្សោយឡើងៗ សឹងឮតែស្នូរដង្ហើមដែលបង្ហួសវែងព្រោះខឹងណែនទ្រូង តែខាងប្រុសបន្តឆ្លើយវិញធ្វើវាហី៖

«ចុះអ្នកណាវិញដែលដឹងរឿង?!»

«វាមិនចេះហែលទឹក វាមានស្មារតីមិនគ្រប់ដប់ទេ ដឹងអត់អ្ហះ ដឹងអត់គីម៉ាល់?» នាងបន្ថែមទាំងបើកភ្នែកធំៗពេញដោយទុក្ខា រលើបរលោងផ្ទាញ់បេះដូង ងងើលរបស់នាយ។

គីម៉ាល់លើកចិញ្ចើមធ្វើហី សម្លឹងប្រតិកម្មទុក្ខសោករបស់នាង ។ ក្នុងទ្រូងនាយប្រាប់ជាសម្ងាត់ថា នារីនេះចាំឈ្មោះខ្លួនច្បាស់ មួយម៉ាត់ហៅឈ្មោះពីរម៉ាត់ហៅឈ្មោះ កោតតែនាងស្គាល់ឈ្មោះមិនស្គាល់ចិត្ត នាងសមនឹងរងព្រមានខ្លះក្រែងបានបង្អន់ចរិតបានចិត្ត ដែលមានពួកប្រុសៗពីរប្រាណនោះជាសំអាង ហ៊ានធ្វើឡូយឆាយផ្ដាច់ទំនាក់ទំនង ទទឹងទិសជាមួយបងថ្លៃម្នាក់នេះ។

ទោះយ៉ាងណា គេបានជ្រើសរើសមិនឆ្លើយតបនាងនៅឡើយទុកឱ្យនាងបញ្ចេញប្រតិកម្មតាមចិត្ត។ នៅក្នុងភាពស្ងៀមស្ងាត់បុរស ឃើញនាងម្ដងងាកទៅទន្លេ ម្ដងងាកមកសម្លឹងនាយ ហាក់ចង់ «សុំជំនួយ» តែនាងនិយាយមិនចេញ ហាមិនកើត «នាងមិនចង់ជំពាក់ជំនួយ ហើយនាងចង់ខែងរ៉ែង»។ គេគិតទាំងសម្លឹងនាងមិនស្ដី។

សន្សឹមៗនាងលូកដៃមកមែន គឺ នាងលូកមកកាន់ប្រអប់ដៃនាយ ដែលមុននេះបានរលាស់ចេញម្តងជាពីរដងព្រោះតែមិនពេញចិត្ត។

«ខ្ញុំបានធ្វើអីឱ្យអ្នកណាឈឺចាប់ទេ? អ្ហះ? ធ្វើអ៊ីចឹងធ្វើអី?»

នាងសួរទាំងដៃម្ខាងកាន់ប្រអប់ដៃបុរសនេះដៃម្ខាងទៀតជូតទឹកភ្នែកយ៉ាងញាប់។

បុរសធ្វើមុខស្មើ មិនញញឹមក៏មិនកំណាច។

នាងនិយាយបន្ថែមទាំងគគ្រូក៖

«ប្អូនខ្ញុំកើតមកកម្សត់ រស់នៅគ្មានន័យអស់មួយជីវិតស្រាប់ហើយ! ខ្លួនក៏ឃើញ ហេតុអីចាំបាច់ធ្វើបាបវា! អ្ហះ? »

នាងនិយាយហាក់ខឹងណាស់ តែដៃនាងលូកមកបន្ថែមទាំងសងខាង គឺមកកាន់កដៃនាយ អង្វរករតែម្តង។ មានអ្វីមួយ ត្រូវបានហុចមក ឆ្លងកាត់ពីមុខនាង។

«រាល់ពេល រាល់ថ្ងៃ ! ប្អូនខ្ញុំបិទទ្វារបន្ទប់ ផឹកស្រាសម្លាប់ខ្លួនឯងចោល! ប្អូនខ្ញុំក៏កើតមកកម្សត់ រស់នៅទន់ខ្សោយអស់មួយជីវិតស្រាប់ហើយ ម៉េចក៏ប្រពន្ធវា ធ្វើឱ្យវារស់បន្តបន្តិចទៀតមិនបាន?»

ដៃស្រីស្អាតរបូតធ្លាក់ពីប្រអប់ដៃបុរសនេះខណៈពេលដែលភ្នែកនាងដៀងសម្លឹងសន្លឹករូបថតនិងឯកសារនានាជុំវិញការផឹកសុរា និងការព្រមានរបស់វេជ្ជបណ្ឌិតសុខុម។ ប្រធានបទនេះ នាងមិនដែលសូម្បីតែគិតទុកមកផង កុំថាឡើយដល់ទៅ មានពាក្យអ្វីយកមកបកស្រាយ។

ភ្នែកនាងតាមសម្លឹងក្រដាសទាំងសំណុំនោះ ហើយលូកដៃសន្សឹមៗទៅទទួលយកមកអានភ្លេចអស់រឿងផ្សេងៗ ពិសេសរឿងទូកតូចដែលចរចេញចាកច្រាំងមុននេះ។

ទោះយ៉ាងណាគីម៉ាល់បានត្រឹមចង់បង្ហាញ ប៉ុន្តែគេមិនបានចង់ឱ្យនាងយកវាទៅអានទេ។ មុនពេលម្រាមហាន់ដាឈោងដល់ គេចាប់ផ្តើមទម្លាក់សន្លឹកក្រដាស ឱ្យចោលរោយរាលទៅលើកម្រាលឈើ។

ស្រីស្អាតងើបមុខសម្លឹងបុរសបងថ្លៃ ។ ភាពឈឺចាប់នឹងភាពសោះអង្គើយរបស់គេ កើតមានផ្ទួនៗកំដរភ្នែកនាង។ នាងដឹងថា រឿងថ្មីនេះ ធំនិងជ្រៅជាងអ្វីដែលខ្លួនអាចបកស្រាយបាន។

«ចង់ថាខ្ញុំជាអ្នកធ្វើឱ្យប្តីខ្លួនឯងស្លាប់?!»

នាងសួរទាំងមិនហ៊ានសម្លឹងគេ ដោយរវើ្នកសម្លឹងឯកសារទាំងអស់នៅលើកម្រាល។

«មិនទាន់ថាអីទាំងអស់! ខ្ញុំចាំស្តាប់ការបកស្រាយ!»

នាងងើបមុខយឺតៗ ហើយគិតបណ្ដើរ ត្រៀមពាក្យពេចន៍បណ្ដើរ។

សំឡេងខាងប្រុសពោលឡើងបន្ថែម៖

«បើមិនបានធ្វើខុស គ្មានអ្នកណាគេចោទប្រកាន់យើងបានទេ!»

នាងតបតភ្លាមៗ៖

«នេះជាលើកដំបូងដែលខ្ញុំដឹងថា គាត់បិទទ្វារញ៉ាំស្រាប្រឆាំងវេជ្ជបញ្ជារបស់ពេទ្យ! ខ្ញុំទើបនឹងដឹងពីគីម៉ាល់ពេលនេះ  ខ្ញុំមិនដែលដឹងនោះទេ! សូម្បីលិខិតព្រមានរបស់ដុកទ័រសុខុម ! សូម្បីតែរឿងដែលគាត់បានកុម្ម៉ង់ស្រាច្រើនដល់ម្លឹង...!»

មិនរង់ចាំឱ្យនាងនិយាយចប់បានឡើយ។ រូបភាពដ៏កម្សត់របស់ពិសិដ្ឋដែលកើតទុក្ខវេទនាម្នាក់ឯងមុនពេលស្លាប់បានអណ្ដែតមកបិទបាំងការអត់ធ្មត់របស់គេ។ គីម៉ាល់និយាយទាំងខាំមាត់ដោយទោសៈ៖

«យើងនេះជាប្រពន្ធធុនស្អីអ្ហះ? ប្រពន្ធធុនស្អីគេ? យើងដឹងស្អីខ្លះពីប្ដីរបស់ខ្លួន? យើងដើរចោលពិសិដ្ឋឱ្យនៅផ្ទះម្នាក់ឯងម្ដងៗរាប់ខែ យើងគិតស្អីហាន់ដា? ប្រពន្ធជើងល្អ! រហូតប្ដីស្លាប់ទាំងគ្មានហេតុផលទុកចោលកេរមហាសាលឱ្យយើងគ្រប់គ្រង យើងទ្រាំចាំ១០០ថ្ងៃក៏មិនបានទៀត ឡើងទូកមករំភើបសប្បាយចោលជើងធូបប្ដីអ្ហះ? មានអីនិយាយអត់? គទេ?!»

នាងនៅស្ងៀមគាំងអណ្ដាតចំពោះបទចោទចំកណ្ដាលៗមុខ និងគ្មានទំនងតែក៏គ្មានទំនុកបដិសេធបាននេះ។ នាងមិនបានយំទៀតទេ ព្រោះបេះដូងកំពុងធ្លាយបែក។ អ្នកដែលស្លាប់ទៅហើយនោះត្បិតតែមិនមែនជាស្នេហា តែគេបានបន្សល់នូវអំពើល្អ គុណបុណ្យ ច្រើនសន្ធឹកដែលនាងត្រូវលេបទឹកភ្នែកចងចាំពេញមួយឆាកជីវិតនេះគ្មានថ្ងៃលុប លាងជ្រះ។

«ខ្ញុំមកធ្វើការ! ដឹងអត់គីម៉ាល់! ខ្ញុំមិនបានដើរលេងទេ! ខ្ញុំដល់ឆ្នាំចុងក្រោយហើយ! ខ្ញុំត្រូវចុះកម្មសិក្សា! ពិសិដ្ឋបានយល់ព្រមហើយ! បើសិនគាត់មិនអនុញ្ញាត ខ្ញុំម៉េចនឹងមកចោលគាត់? បើគាត់មិនពេញចិត្តទេ គាត់គួរប្រាប់ខ្ញុំ!»

គេថយទៅអង្គុយចំខែងលើកៅអីឈើវែងដែលស្ថិតនៅអមខាងជញ្ជាំងជ្រុងបន្ទប់ ហើយចាប់ផ្ដើមចុចទូរសព្ទ។ ចុចរួច គីម៉ាល់បង្វែរអេក្រង់មកខាងនាង។

នារីនេះដើរមួយៗ ទៅក្បែរហើយឈ្ងោកពិនិត្យ។

នាងអង្គុយចុះយឺតៗដោយមិនដឹងខ្លួន ខណៈរូបរាងពិសិដ្ឋលេចឡើងមក។ គេហាក់មិនសប្បាយចិត្តខ្លាំង អង្គុយម្នាក់ឯងលើកៅអីក្នុងសួននៃផ្ទះថ្មី ដែលបានទិញរួមរស់ជាមួយគ្នាក្រោយពេលរៀបការរួច។

លើតុមូលតូចនោះមានសុរាទាំងដប ។

នាងពិតជាមិនដែលដឹងទេ។ គេមិនដែលញ៉ាំស្រាទេ ហើយក៏មិនមានសញ្ញាសុខភាពធ្វើទុក្ខអ្វីដែររាល់ពេលនាងឡើងពីស្ទឹងត្រែងវិលទៅផ្ទះម្ដងៗ។

គីម៉ាល់លើកដៃដាក់ស្មើបបូរមាត់សម្លឹងទៅដងទន្លេដែលឯកាក្រៀមស្រពោនក្រោមរាត្រីកាល។ កូនតូចឈប់ចតកណ្ដាលទន្លេ។ គេដឹងថានិវត្តកំពុងជាប់ចិត្តនឹងការថតយកអំពិលអំពែកតាមរបៀបដែលគេទើបនឹងបង្រៀន។

«លោកនេះគ្មានអ្នកណាថតអំពិលអំពែកបាននោះទេបងសិដ្ឋ»

«បងឈ្មោះគីម៉ាល់!» អ៊ុនខំឱនប្រាប់ តែក្នុងចិត្តប្អូនប្រុសហាន់ដា គីម៉ាល់នៅតែជាសិដ្ឋ។

កម្លោះមិនគ្រប់ដប់ ទោះជាមិនយល់ការអ្វីធំដុំប៉ុន្តែគេអាចដឹងថាអំពិលអំពែកជាអ្វីមួយដែលមើលមិនងាយទាន់ ចាប់មិនជាប់ ផ្ដិតថតមិនបាន ទោះបីជាឌីជីថលមានកម្រិតល្បឿនរហ័សបែបណានិងសមត្ថភាពឆក់បានលើសកម្លាំងភ្នែកមនុស្សធម្មតាយ៉ាងណាក្ដី។

ពេលនេះគេជឿថា វិធីថតដែលគីម៉ាល់ទើបបង្រៀនមុខតែបានផល បានជាគេឡើងទូកទៅ។ នារីនេះភាន់ភាំងស្មានថា គេយកប្អូននាងទៅជ្រមុជទឹកផងក៏មិនដឹង ចំណែកពេលនេះ បានឃើញវីដេអូប្ដីក៏ភ្លេចភ្លាំងលែងនឹកឃើញដល់ប្អូនបានភ្លាមៗ។

ស្រីស្លើតស្លក់!

បុរសបន្ទោសតិចៗក្នុងគំនិតម្នាក់ឯងមិនបានបញ្ចេញសំឡេងអ្វីឱ្យនាងដឹងឡើយ។

គេមើលសកម្មភាពរបស់នាងផង ចិត្តវិភាគរាប់រយជំពូកអំពីនារីនេះ ទាំងក្នុងបេះដូងមានក្ដៅមានត្រជាក់ទាក់ទងនឹងប្រធានបទ«នាង»។

ហាន់ដាលែងរវល់ពីអ្វីទាំងអស់។ នាងផ្ដោតសម្លឹងរូបស្វាមីកម្សត់ដែលអានសំណុំឯកសារអ្វីម្យ៉ាងទំនងជាដុំរូបថត ចេញពីក្នុងស្រោមសំបុត្រធំមួយ។ មើលហើយគេគ្រវាត់គ្រវែងវា ទាំងកំហឹងទៅលើដីហើយទ្រោបក្បាលរង្កើស្មាទាំងសងទំនងដូចជាយំសោក។

នាងមិនធ្លាប់ដឹងទេថាពិសិដ្ឋឆ្លងកាត់ពេលវេលាទុក្ខសោកជាច្រើន បែរជាលាក់ទុកក្នុងចិត្តតែម្នាក់ឯង។ ពេលប្រពន្ធមកម្តងៗ គេធ្វើម្ហូប ញញឹមញញែម លួងចិត្តនិយាយល្អៗ នាំនាងដើរលេង មិនដែលសូម្បីបន្សល់សម្តីល្អក់កករមួយម៉ាត់ណា។

«រូបអីគេ? រូបថតអ្នកណាហេតុអីគេឈឺចាប់ម្ល៉េះប្រាប់ខ្ញុំមក!»

នាងនិយាយទាំងចុកពើតក្នុងទ្រូង មុនពេលងើបមុខសន្សឹមៗសម្លឹងម្ចាស់បន្ទប់។

គីម៉ាល់ ជាមួយកែវភ្នែកស្រងូត បបូរមាត់ក្រៀមក្រោះគ្មានស្នាមសំណើច គេលូកទៅក្រោមតុហុចសំណុំរូបថតទៅឱ្យនាង។